# សេចក្តីថ្លែងការណ៍រួម

## តុលាការគួរធ្វើការស៊ើបអង្កេតករណីបណ្តឹងរបស់កញ្ញា មាន ពេជ្ររីតា ក្នុងបទប៉ុនប៉ងរំលោភសេពសន្ថវៈ ឱ្យបានគ្រប់ជ្រុងជ្រោយនិងប្រកបដោយតម្លាភាព

ថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០២១ -- អង្គការ សមាគមសារព័ត៌មាន អង្គការសមាគមមិនមែនរដ្ឋាភិបាល បណ្តាញអ្នកសារព័ត៌មានដែលមានរាយនាមខាងក្រោម ជំរុញឱ្យតុលាការធ្វើការស៊ើបអង្កេតឱ្យបានគ្រប់ជ្រុងជ្រោយនិងប្រកបដោយតម្លាភាព លើពាក្យបណ្តឹងរបស់ពិធីការិនីទូរទស្សន៍ My TV កញ្ញា មាន ពេជ្ររីតា (ហៅយូប៊ី) ដែលចោទប្រកាន់ឧកញ៉ា ហេង សៀ ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ ។

កាលពីថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០២១ កញ្ញា មាន ពេជ្ររីតា ហៅយូប៊ី ជានិស្សិតឆ្នាំទី២ផ្នែកជំនួញពាណិជ្ជកម្មនិងជាពិធីការិនីបម្រើការនៅស្ថានីយ៍ទូរទស្សន៍ My TV បានដាក់ពាក្យប្តឹងប្រឆាំងឧកញ៉ា ហេង សៀ ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅក្នុងរថយន្តនៅម្តុំផ្សារគីឡូលេខ ៤ ជិតសាកលវិទ្យាល័យអាស៊ីអឺរ៉ុប។

បើតាមការរៀបរាប់របស់កញ្ញា មាន ពេជ្ររីតា នៅក្នុងពាក្យបណ្តឹងជូនដល់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញឱ្យដឹងថា កាលពីថ្ងៃទី ៤ខែឧសភា វេលាម៉ោងប្រមាណ ១៤:00 ទៅម៉ោង ១៥:00 នាទីរសៀល លោកឧកញ៉ា ហេង សៀ បានទូរស័ព្ទមកកញ្ញាប្រាប់ថា ចង់ជួបនិងឱ្យអីវ៉ាន់មកកញ្ញាដែលមានដូចជា អង្ករ ទឹកត្រីជាដើម ដើម្បីចែកអំណោយទៅប្រជាពលរដ្ឋដែលទទួលរងគ្រោះដោយសារជំងឺកូវីដ ដោយបានឱ្យកញ្ញាចាំនៅក្បែរផ្សារគីឡូលេខ ៤ ជិតសាកលវិទ្យាល័យអាស៊ីអឺរ៉ុប រួចក៏បង្ខំឱ្យកញ្ញាចូលក្នុងឡាន។ កញ្ញាបានរៀបរាប់បន្តថា បន្ទាប់ពីកញ្ញាបានចូលទៅក្នុងឡានរួច ឧកញ៉ា ហេង សៀ បាននិយាយពាក្យអាសអាភាសដាក់កញ្ញា រួចក៏យកដៃមកលូកស្ទាបអង្អែលភ្លៅនិងប្រដាប់ភេទរបស់កញ្ញាជាញឹកញាប់ និងបាននិយាយថា គាត់មានអារម្មណ៍ចង់រួមភេទខ្លាំងណាស់ហើយចង់យកកញ្ញាទៅផ្ទះសំណាក់ ពេលនោះកញ្ញាមិនព្រម និងចង់លោតចុះពីលើឡាន ប៉ុន្តែឧកញ៉ា ហេង សៀ គំរាមថាគាត់មានកាំភ្លើង។ ក្រោយពេលឮដូច្នោះរួចកញ្ញាមានការភិតភ័យក៏បានរត់មកកៅអីឡានខាងក្រោយ ហើយឧកញ៉ាបានឈប់ឡាន និងបានយកដៃរបស់គាត់មកចាប់សង្រ្គប់លើរូបកញ្ញា ហើយកញ្ញាបានបានខំរើបំរះនិងបានបើកទ្វារឡានរត់ចេញ និងបានរត់ទៅផ្ទះវិញទាំងការភិតភ័យបំផុត។ នៅក្នុងករណីនៃការចោទប្រកាន់របស់កញ្ញា ពេជ្ររីតា គាត់គឺជាជនរងគ្រោះនៃការប៉ុនប៉ងរំលោភសេពសន្ថវៈពីឧកញ៉ា ហេង សៀ។ ក៏ប៉ុន្តែផ្ទុយទៅវិញ កញ្ញា ពេជ្ររីតា ត្រូវបានសមត្ថកិច្ចឃុំខ្លួនរយៈពេលពីរថ្ងៃគឺចាប់ពីថ្ងៃទី៨ ខែឧសភា ហើយបន្ទាប់ពីនោះសាលាដំបូងរាជធានីភ្នំពេញបានចោទប្រកាន់គាត់ពីបទលួចមានស្ថានទម្ងន់ទោស (លួចទូរស័ព្ទដៃ ដោយប្រើហិង្សាបណ្តាលឱ្យឧកញ៉ាម្នាក់រងរបួស)។

នៅក្នុងវីដេអូកាម៉េរ៉ាសុវត្ថិភាពដែលត្រូវបានផ្សព្វផ្សាយ រួមជាមួយនឹងការចេញផ្សាយរបស់សារព័ត៌មានក្នុងស្រុកមួយចំនួន យើងខ្ញុំយល់ឃើញថា មានភាពមិនប្រក្រតីមួយចំនួនដែលទាមទារឱ្យមានការស៊ើបអង្កេតឱ្យបានគ្រប់ជ្រុងជ្រោយ និងប្រកបដោយតម្លាភាព ដើម្បីធានាថាជនរងគ្រោះនឹងមិនក្លាយជាជនល្មើស ហើយយុត្តិធម៌ត្រូវបានផ្តល់ជូនយ៉ាងពិតប្រាកដដល់ភាគីទាំងសង្ខាង។

ជាមួយគ្នានេះដែរ យើងខ្ញុំក៏អំពាវនាវដល់អ្នកសារព័ត៌មាន ក៏ដូចជាស្ថាប័នសារព័ត៌មានទាំងអស់សូមធ្វើសេចក្តីរាយការណ៍ដោយផ្អែកលើមូលដ្ឋានវិជ្ជាជីវៈ ជៀសវាងការសរសេរព័ត៌មានដែលជាការដាក់បន្ទុកដល់ភាគីណាមួយដោយមិនមានប្រភព ឬភស្តុតាងរឹងមាំ និងមិនមានព័ត៌មានគ្រប់ជ្រុងជ្រោយ៕

ស្ថាប័នដែលបានចូលរួមគាំទ្រសេចក្តីថ្លែងការណ៍នេះមាន៖

1. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍
2. អ្នកសារព័ត៌មានស្ត្រីនៅកម្ពុជា (CFJ)
3. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)